Absolutely Positively
**Wellington** City Council
Me Heke Ki Pōneke

# ការផ្លាស់ប្តូរម្ចាស់ផ្ទះជួលទៅ Te Toi Mahana (អ្នកផ្តល់លំនៅដ្ឋានសហគមន៍) សន្លឹកព័ត៌មានសម្រាប់អ្នកជួលទីលំនៅ (ខែកក្កដា ឆ្នាំ 2023)

ចាប់ពីថ្ងៃទី 1 ខែសីហា ឆ្នាំ 2023 Te Toi Mahana ដែលជាអ្នកផ្តល់លំនៅដ្ឋានសហគមន៍ថ្មី នឹងក្លាយជាម្ចាស់ផ្ទះជួលរបស់អ្នក។ ខាងក្រោមនេះគឺជាព័ត៌មានសំខាន់ៗមួយចំនួនអំពីការផ្លាស់ប្តូរនេះ។

## តើកិច្ចព្រមព្រៀងជួលទីលំនៅរបស់ខ្ញុំនឹងផ្លាស់ប្តូរទេ?

ទេ។ កិច្ចព្រមព្រៀងជួលទីលំនៅរបស់អ្នកនឹងផ្ទេរពីសាលាក្រុង Wellington ទៅ Te Toi Mahana។ អ្នកនឹងមានថ្លៃឈ្នួលផ្ទះដូចគ្នា និងលក្ខខណ្ឌជួលទីលំនៅដូចគ្នា។ យើងនឹងសរសេរទៅអ្នកក្នុងខែកក្កដា ដើម្បីបញ្ជាក់អំពីរឿងនេះដោយស្របច្បាប់។ អ្នកនឹងមិនចាំបាច់ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងជួលទីលំនៅថ្មីទេ។ ការជួលទីលំនៅរបស់អ្នកគឺមានសុវត្ថិភាព។

## តើខ្ញុំត្រូវបង់ថ្លៃឈ្នួលផ្ទះឱ្យទៅអ្នកណាបន្ទាប់ពីថ្ងៃទី1 ខែសីហា?

បន្ទាប់ពីថ្ងៃទី1 ខែសីហា អ្នកត្រូវបង់ថ្លៃឈ្នួលផ្ទះរបស់អ្នកទៅ Te Toi Mahana។ អ្នកនឹងត្រូវធ្វើបច្ចុប្បន្នភាពលេខគណនីធនាគារដែលអ្នកបង់ថ្លៃឈ្នួលផ្ទះចូលទៅ។ ការបង់ថ្លៃឈ្នួលផ្ទះជួលបន្ទាប់ពីថ្ងៃទី 1 ខែសីហា គួរតែបានបង់ទៅ៖

គណនី Te Toi Mahana ៖ **01 - 1839 - 0947157 - 02**

## តើនឹងមានអ្វីកើតឡើងចំពោះប្រាក់បង់ធានាការជួលទីលំនៅរបស់ខ្ញុំ?

**ប្រាក់បង់ធានា**របស់អ្នកនឹងត្រូវបានផ្ទេរពី City Housing g ទៅ Te Toi Mahana។ អ្នកមិនចាំបាច់ធ្វើអ្វីទេ។ **ប្រាក់បង់ធានា**ទាំងអស់នឹងបន្តកាន់កាប់ដោយសេវាកម្មជួលទីលំនៅ។

## តើនឹងមានការតម្លើងថ្លៃឈ្នួលផ្ទះដែរឬទេ?

ការបង្កកថ្លៃឈ្នួលផ្ទះបច្ចុប្បន្ននឹងនៅដដែលរហូតដល់ខែកញ្ញា ឆ្នាំ 2023។ ការផ្លាស់ប្តូរថ្លៃឈ្នួលផ្ទះណាមួយបន្ទាប់ពីពេលនោះ នឹងក្លាយជាការសម្រេចចិត្តរបស់ Te Toi Mahana។ ប្រសិនបើថ្លៃឈ្នួលផ្ទះរបស់អ្នកផ្លាស់ប្តូរ អ្នកនឹងត្រូវបានគេជូនដំណឹងយ៉ាងហោចណាស់បីខែ ។

## តើការបង្កកថ្លៃឈ្នួលផ្ទះ 80+ និងការកំណត់ថ្លៃឈ្នួលផ្ទះផ្សេងទៀតនៅមានដដែលឬ?

ពិតមែនហើយ។ ប្រាក់ឧបត្ថម្ភដែនកំណត់ថ្លៃឈ្នួលផ្ទះដែលឈ្មួមនឹងចំណាយបាន ការដាក់កម្រិតថ្លៃឈ្នួលផ្ទះ និងការបង្កកថ្លៃឈ្នួលផ្ទះ 80+ នឹងផ្ទេរទៅ Te Toi Mahana។

## តើខ្ញុំទាក់ទង Te Toi Mahana ដោយរបៀបណា?

**ចាប់ពីថ្ងៃទី 1 ខែសីហា អ្នកអាចទាក់ទង Te Toi Mahana តាមរយៈ៖**

| | |
|---|---|
| ទូរសព្ទ៖ | 0800 248 944 |
| អ៊ីមែល៖ | info@tetoimahana.org.nz |
| គេហទំព័រ៖ | www.tetoimahana.org.nz |
| អាសយដ្ឋាន៖ | Te Toi Mahana, DX Mail SP2550, Wellington, 6011 |

## តើប្រាក់ឧបត្ថម្ភកន្លែងស្នាក់នៅផ្អែកលើការងារ និងប្រាក់ចំណូលនឹងរងផលប៉ះពាល់ដោយសារការផ្លាស់ប្តូរទៅ Te Toi Mahana ដែរឬទេ?

ទេ។ អ្នកនឹងត្រូវបន្តធ្វើបច្ចុប្បន្នភាពលើការងារ និងប្រាក់ចំណូល/MSD ដើម្បីធានាថាអ្នកកំពុងទទួលបានកម្រិតត្រឹមត្រូវនៃការគាំទ្រសម្រាប់ថ្លៃឈ្នួលផ្ទះរបស់អ្នក។

### តើខ្ញុំនៅតែអាចប្រើមជ្ឈមណ្ឌលសេវាកម្មសាលាក្រុង Wellington នៅផ្លូវ Manners Street ដែរឬ?

ពិតមែនហើយ រហូតដល់មានការជូនដំណឹងបន្ថែម។ អ្នកនឹងអាចបង់ថ្លៃឈ្នួលផ្ទះរបស់អ្នកទៅ Te Toi Mahana រៀបចំលិខិតអនុញ្ញាតចតរថយន្ត ឬធ្វើការសាកសួរនៅមជ្ឈមណ្ឌលសេវាកម្មសាលាក្រុង Wellington។

### តើខ្ញុំធ្វើកំណត់ត្រាការងារជួសជុលដោយរបៀបណា?

*រហូតដល់ថ្ងៃទី31 ខែកក្កដា ឆ្នាំ2023*

- ទូរសព្ទទៅសាលាក្រុងតាមលេខ 04 499 4444 ឬ
- ប្រើទម្រង់បែបបទជួសជុលរបស់សាលាក្រុង Wellington តាមរយៈគេហទំព័រ wellington.govt.nz/report-a-problem ឬ
- **ធ្វើកំណត់ត្រាការងារជួសជុល**នៅក្នុងកម្មវិធី FIXiT app

*ចាប់ពីថ្ងៃទី1 ខែសីហា ឆ្នាំ2023*

- ទូរសព្ទ ឬអ៊ីមែល Te Toi Mahana ឬ
- លើករឿង**ការងារជួសជុល**ជាមួយអ្នកប្រឹក្សាជួលទៅលំនៅរបស់អ្នក។

### តើអ្នកណានឹងក្លាយជាទីប្រឹក្សាជួលទីលំនៅរបស់ខ្ញុំ?

បុគ្គលិក City Housing ភាគច្រើន នឹងបន្តតួនាទីស្រដៀងគ្នាជាមួយ Te Toi Mahana រួមទាំង**ទីប្រឹក្សាជួលទីលំ**នៅ ក្រុមអភិវឌ្ឍន៍ សហគមន៍ និងក្រុមជួសជុលគ្រឿងបរិក្ខារ។ Te Toi Mahana នឹងបញ្ជាក់ ហើយណែនាំទីប្រឹក្សាជួលទីលំនៅរបស់អ្នក នៅពេលដែល ពួកគេចូលកាន់កាប់ក្នុងខែសីហា។

### តើ Te Toi Mahana នឹងជ្រើសរើសអ្នកជួលថ្មីដោយរបៀបណា?

នៅពេលទីលំនៅទំនេរ Te Toi Mahana នឹងរកអ្នកជួលថ្មីចេញពីបញ្ជីលំនៅដ្ឋានរដ្ឋ MSD។

### តើអ្នកនឹងធ្វើបច្ចុប្បន្នភាពផ្លាកសញ្ញាទេ?

ពិតមែនហើយ យើងនឹងធ្វើបច្ចុប្បន្នភាពផ្លាកសញ្ញានៅអគារលំនៅដ្ឋាន ដើម្បីឆ្លុះបញ្ចាំងពី Te Toi Mahana។ យើងនឹងយកចេញស្លាកសញ្ញារបស់សាលាក្រុង Wellington។ ការនេះនឹងចំណាយពេលខ្លះដើម្បីបញ្ចប់ ដូច្នេះអ្នកអាចនឹងកត់សម្គាល់ឃើញការផ្លាស់ប្តូរទៅតាមពេលវេលា។ អ្នកម៉ៅការមួយចំនួនដែលបំពេញការងារនៅផ្ទះរបស់អ្នក ប្រហែលជានៅបន្តប្រើយានជំនិះ និងឯកសណ្ឋានរបស់សាលាក្រុងក្នុងអំឡុងពេលផ្លាស់ប្តូរនេះ។

### តើមានការគាំទ្រអ្វីខ្លះសម្រាប់អ្នកជួលទីលំនៅដែលមិននិយាយភាសាអង់គ្លេស?

ប្រសិនបើអ្នកត្រូវការជំនួយជាភាសារបស់អ្នក សូម៖

- ទូរសព្ទទៅសាលាក្រុងតាមលេខ 04 499 4444 ហើយសុំអ្នកបកប្រែផ្ទាល់មាត់។ មានផ្តល់ជូនច្រើនជាង 60 ភាសា
- និយាយទៅកាន់ទីប្រឹក្សាជួលទីលំនៅរបស់អ្នក ពួកគេអាចរៀបចំជំនួយភាសា និងអ្នកបកប្រែផ្ទាល់មាត់
- សន្លឹកព័ត៌មាននេះមានជាភាសា Te Reo Māori ចិនកុកងឺ អេស្ប៉ាញ អារ៉ាប់ ហ្វាស៊ី សាម័រ តាមីល ហិណ្ឌូ ខ្មែរ រុស្ស៊ី សូម៉ាលី និងកូមា។ មាននៅលើគេហទំព័រ wellington.govt.nz/community-housing-provider និងពីទីប្រឹក្សាជួលទីលំនៅ។

### តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅឯណា?

អ្នកអាចស្វែងរកព័ត៌មានបន្ថែម៖

- តាមអនឡាញនៅ wellington.govt.nz/community-housing-provider
- ពីទីប្រឹក្សាជួលទីលំនៅរបស់អ្នក
- នៅក្នុងសំបុត្ររបស់យើងផ្ញើទៅអ្នក

- នៅក្នុងព្រឹត្តិបត្រព័ត៌មានអ្នកជួលទីលំនៅ។